# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)

## កិច្ចប្រជុំលើកទី 17

14 វិច្ឆិកា 2024

ទីតាំង៖ Taunton Public Library, 12 Pleasant St, Taunton MA
ម៉ោង 6:30 ល្ងាច ដល់ 8:00 យប់

## កំណត់ហេតុកិច្ចប្រជុំ

ទីកន្លែងប្រជុំ៖ ដោយផ្ទាល់

ឯកសារកិច្ចប្រជុំ៖ របៀបវារៈ, ស្លាយ

សមាជិកក្រុមប្រឹក្សាដែលមានវត្តមាន៖

- María Belén Power អនុរដ្ឋលេខាក្រុមប្រឹក្សា EEA ផ្នែកយុត្តិធម៌បរិស្ថាននិងសមធម៌ (EJ & Equity) (ផ្ទាល់)
- Kalila Barnett (អវត្តមាន)
- Madeline Fraser Cook (អវត្តមាន)
- Melissa Ferretti (ពីចម្ងាយ)
- Cheryll Holley (ពីចម្ងាយ)
- Caroline Hon (ផ្ទាល់)
- Namrita Kapur (អវត្តមាន)
- Lydia Lowe (ពីចម្ងាយ)
- Marcos Luna (ផ្ទាល់)
- Peter Maathey (ពីចម្ងាយ)
- Sofia Owen (ពីចម្ងាយ)
- Jen Salinetti (ផ្ទាល់)
- Patricia Spence (ពីចម្ងាយ)
- Ari Zorn (អវត្តមាន)
- Miles Gresham (អវត្តមាន)

បុគ្គលិកការិយាល័យប្រតិបត្តិថាមពលនិងកិច្ចការបរិស្ថាន (EEA) ដែលមានវត្តមាន៖

- Caroline Lemoine អនុប្រធាន EEA
- Jonathan Guzman ប្រធាន EEA
- Martha Grover ទីប្រឹក្សាគោលនយោបាយសម្រាប់ការកាត់បន្ថយបំភាយកាបូនពីក្នុងអគារ

បុគ្គលិកផ្សេងៗដែលមានវត្តមាន៖

- Dylan Voorhees អ្នកពិគ្រោះយោបល់ជាន់ខ្ពស់នៅស្ថាប័ន VEIC

1. **មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ**

   Kecil John បានជម្រាបជូនពីទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ រួមទាំងការប្រើប្រាស់ប្រអប់សំណួរនិងចម្លើយ (Q&A) និងលទ្ធភាពអាចទទួលបានអ្នកបកប្រែផ្ទាល់មាត់។ María Belén Power បានស្វាគមន៍អ្នកចូលរួមទាំងអស់។

2. **ទិដ្ឋភាពទូទៅនៃរបៀបវារៈ**

**María Belén Power** បានរំលឹកឡើងវិញអំពីរបៀបវារៈនៃកិច្ចប្រជុំ។

3. **ការហៅឈ្មោះសមាជិក/ការអនុម័តលើកំណត់ហេតុប្រជុំពីមុន**

   **María Belén** បានធ្វើការហៅឈ្មោះសមាជិកក្រុមប្រឹក្សា EJC។ នៅពេលចាប់ផ្ដើមកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សាដូចខាងក្រោមបានមានវត្តមានចូលរួម។ **Kalila Barnett, Madeline Fraser Cook, Melissa Ferretti, Cheryll Holley, Caroline Hon, Lydia Lowe, Marcos Luna, Peter Maathey, Sofia Owen, Jen Salinetti, Patricia Spence និង María Belén Power**។

   សមាជិកក្រុមប្រឹក្សាដូចខាងក្រោមមិនមានវត្តមានចូលរួម៖ **Ari Zorn, Miles Gresham,** និង **Namrita Kapur**។

   **María Belén** បើកឱកាសឱ្យមានការដាក់ជូនសំណើដើម្បីអនុម័តលើកំណត់ហេតុពីកិច្ចប្រជុំលើកមុន។ **Melissa Ferretti** បានស្នើសុំឱ្យយល់ព្រម។ **Jen Salinetti** បានគាំទ្រសំណើ។ រាល់សមាជិកក្រុមប្រឹក្សាដែលមានវត្តមានទាំងអស់បានទទួលយកកំណត់ត្រា លើកលែង **Cheryll Holley និង Caroline Hon** មិនបានបោះឆ្នោតគាំទ្រ ដោយសារតែមិនបានចូលរួមកិច្ចប្រជុំពីមុន។

4. **វគ្គសំណួរនិងចម្លើយជាសាធារណៈលើកទីមួយ**
   ទាំងសាធារណជនចូលរួមតាមអនឡាញនិងដោយផ្ទាល់ សុទ្ធតែបានផ្ដល់មតិយោបល់ សំណួរ និងស្នើសុំ។
   - អ្នកចូលរួមជាច្រើនបានចែករំលែកបទពិសោធន៍របស់ពួកគេអំពីអយុត្តិធម៌បរិស្ថានដែលសហគមន៍របស់ពួកគេកំពុងជួបប្រទះនៅទីក្រុង Taunton រដ្ឋម៉ាសាឈូសិត ។ អ្នកចូលរួម
     រៀបរាប់លម្អិតអំពីបទពិសោធន៍សហគមន៍របស់ពួកគេដែលប្រឈមមុខនឹងផលប៉ះពាល់បរិស្ថាននៃការរស់នៅក្បែររោងចក្រឧស្សាហកម្មហ៍ជាច្រើន។ សហគមន៍ជួបប្រទះនូវសំឡេងរំខាន ធូលី ចរាចរកកកុញ និងផលប៉ះពាល់ដល់សុខភាព ជាពិសេសបញ្ហាផ្លូវដង្ហើម។ សហគមន៍មានការពិបាកក្នុងការទាក់ទងទៅកាន់ភ្នាក់ងារក្នុងស្រុកនិងសហព័ន្ធរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ទាំងនេះ។
   - អ្នកចូលរួមម្នាក់ចាប់អារម្មណ៍ចង់ស្វែងយល់ពីមូលហេតុថាហេតុអ្វីបានជា EJC មានរយៈពេលផ្ដល់យោបល់ចំនួនពីរ។ អ្នកចូលរួមបានស្នើសុំឱ្យមានការពន្យល់បកស្រាយអំពីរបៀបដែល EJC ធ្វើការសន្និដ្ឋានសម្រេចរួមបញ្ចូលរយៈពេលផ្ដល់យោបល់ចំនួនពីរនៅក្នុងអំឡុងពេលកិច្ចប្រជុំ។

5. **បទបង្ហាញពីគម្រោង Clearinghouse របស់ស្ថាប័ន VEIC**
   Dylan Voorhees ជាវាគ្មិន បានផ្ដល់បទបង្ហាញស្ដីពីគម្រោង Clearinghouse របស់ស្ថាប័ន VEIC ដែលជាក្រុមហ៊ុនពិគ្រោះយោបល់។ VEIC ជាក្រុមហ៊ុនផ្ដល់សេវាថាមពលមិនរកប្រាក់ចំណេញធ្វើការជាអន្តជាតិលើគម្រោងកម្ដៅស្អាត។ ដោយមានការប្រឹក្សាយោបល់ និងការណែនាំពី EEA គម្រោង Clearinghouse បានបង្កើតគណៈកម្មាធិការទីប្រឹក្សាសមធម៌បណ្ដោះអាសន្ន ដើម្បីប្រមូលគំនិតយល់ឃើញនានាអំពីសមធម៌ពីក្នុងរដ្ឋទាំងមូល។ គណៈកម្មាធិការប្រឹក្សាបានបំពេញការងារដើម្បីជួយសម្រេចចិត្តអំពីរបៀបបង្កើតប្រព័ន្ធបណ្ដុំព័ត៍មានជនធានថាមពលប្រកបដោយសមធម៌សម្រាប់ជម្រើសថាមពលជំនួស។ ទីបំផុត ប្រព័ន្ធបណ្ដុំព័ត៍មានជនធានថាមពលនេះ នឹងជួយណែនាំអតិថិជនក្នុងការជ្រើសយកជម្រើសថាមពលជំនួសដែលត្រឹមត្រូវ។

សមាជិកក្រុមប្រឹក្សាបានសាកសួរអំពីការបង្កើតវិធីដែលដោះស្រាយបញ្ហាទំនាក់ទំនងរវាងម្ចាស់ផ្ទះជួលនិងអ្នកជួល ការបកស្រាយបំភ្លឺអំពីគោលដៅនៃប្រព័ន្ធបណ្តុំព័ត៌មានធនធានថាមពលនៅរដ្ឋម៉ាសាឈូសិត និងបានស្នើសុំព័ត៌មានជាមូលដ្ឋានបន្ថែមទៀតអំពីការចូលរួមរបស់ភាគីពាក់ព័ន្ធ។

**មតិយោបល់ពីសំណួរនិងចម្លើយ មានរៀបរាប់ដូចខាងក្រោម៖**

| # | សំណួរ | ឈ្មោះអ្នកសួរ | ចម្លើយ |
|---|---|---|---|
| **1** | នៅក្នុងការបោះឆ្នោតនាពេលថ្មីៗនេះ អ្នកបោះឆ្នោតនៅចុងតំបន់ Cape Cod បានជំទាស់នឹងសំណើសុំបង្កើតគម្រោងថាមពលខ្យល់ក្រៅឆ្នេរក្នុងមហាសមុទ្របន្ថែមទៀត។ តើ EOEEA នៃរដ្ឋម៉ាសាឈូសិត នឹងចាត់វិធានការដើម្បីដោះស្រាយបញ្ហាប្រឆាំងជំទាស់ទៅនឹងថាមពលកកើតឡើងវិញនេះដោយរបៀបណា? | អានាមិក | គ្មាន |

6. **ជំហានបន្ទាប់ និងការលើកវារកាល**

   **María Belén** បានរំលឹកសមាជិកក្រុមប្រឹក្សាអំពីកាលបរិច្ឆេទនៃកិច្ចប្រជុំបន្ទាប់នៅ**ថ្ងៃទី 09 ខែមករា នៅទីក្រុង Lowell** ។ **María Belén** បានជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាថា ឆាប់ៗនេះ EEA នឹងបិទផ្សាយសំណើសុំការឆ្លើយតប ដើម្បីទទួលបានដៃគូសមធម៌ចំនួនប្រហែល 5 ដើម្បីជួយសហគមន៍នៅក្នុងដំណើរការធ្វើផែនការ MVP Planning 2.0 ហើយការឆ្លើយតបនឹងផុតកំណត់នៅពាក់កណ្តាលខែធ្នូ។

   **María Belén** បានស្នើសុំផ្អាកការប្រជុំ។ **Caroline Hon** បានស្នើសុំផ្អាកការប្រជុំ។ **Jen Salinetti** បានគាំទ្រ។ កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង **7:40** យប់។